ភាសាខ្មែរ – Khmer

Australian Government
Department of Education, Employment and Workplace Relations

NDCO
National Disability Coordination Officer Program

# កម្មវិធីមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិ

**កម្មវិធីមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិប្រើ ប្រាស់បណ្តាញការងារទូទាំងប្រទេសអូស្ត្រាលីដែលមានមន្ត្រីចំនួន ៣១ រូបដើម្បីផ្តល់ព័ត៌មាន ការសម្របសម្រួល និងសេវាបង្អែកសម្រាប់ជនពិការដែលកំពុងស្វែងរក (ឬបានចុះឈ្មោះចូលរៀន) វគ្គអប់រំក្រោយសាលាចំណេះទូទៅ និងវគ្គបណ្តុះបណ្តាលនានាដើម្បីជួយពួកគេឱ្យទទួលបានការងារ។**

**មន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិក៏នឹងបង្កើតការផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងគ្រប់ផ្នែកអប់រំ បណ្តុះបណ្តាល និងការងារ ដើម្បីឱ្យជនពិការទទួលបានជំនួយនៅគ្រប់លំដាប់ថ្នាក់។**

រដ្ឋាភិបាលអូស្ត្រាលីយល់អំពីការលំបាកដែលជនពិការកំពុងប្រឈមមុខ និងទទួលស្គាល់អំពីតម្រូវការ នៃការគាំទ្រអន្តរកាលដើម្បីជួយឱ្យជនពិការចូលរួមយ៉ាងពេញទំហឹងក្នុងការអប់រំ បណ្តុះបណ្តាល និងការងារ។

កម្មវិធីមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិដែលមានកញ្ចប់ថវិកា ១៨.៣លានដុល្លាររបស់រដ្ឋាភិបាល អូស្ត្រាលី មានគោលដៅកាត់បន្ថយឧបស័គ្គនានាដែលជនពិការប្រឈមក្នុងការទទួលការអប់រំក្រោយសាលាចំណេះទូទៅ និងការបណ្តុះបណ្តាលនានា និងការបញ្ចប់ប្រកបដោយជោគជ័យ តាមរយៈបណ្តាញថ្នាក់ជាតិដ៏ទូលំទូលាយមួយរបស់មន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិទាំង ៣១ រូប។

## តើកម្មវិធីមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិជាអ្វី?

កម្មវិធីមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិខិតខំព្យាយាមដើម្បីសម្រេចឲ្យមានការសម្របសម្រួលទូទាំងប្រទេសអូស្ត្រាលី និងការផ្តល់សេវាអន្តរកាលដល់ជនពិការដែលកំពុង ឬដែលនឹងចូលរៀននៅតាមសាលាមធ្យមសិក្សា សាកលវិទ្យាល័យ ឬតាមគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

គោលបំណងរបស់កម្មវិធីមន្ត្រីសម្របសម្រួលជន ពិការថ្នាក់ជាតិគឺ:

- ធ្វើឱ្យអន្តរកាលកាន់តែប្រសើរឡើង ដើម្បីជួយជនពិការចេញពីសាលា ឬពីសហគមន៍ឱ្យបានចូលរៀនវគ្គអប់រំក្រោយសាលាចំណេះទូទៅ និងវគ្គបណ្តុះបណ្តាលនានា ហើយក្រោយមកទៀតពួកគេនឹងរកបានការងារធ្វើ។
- បង្កើនការចូលរួមដោយជនពិការនៅឧត្តម សិក្សា ការបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈ និងការងារ។
- បង្កើតការផ្សារភ្ជាប់ឱ្យកាន់តែប្រសើររវាង សាលារៀន សាកលវិទ្យាល័យ គ្រឹះស្ថាន បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស, គ្រឹះស្ថានបណ្តុះបណ្តាល និយោជក និងទីភ្នាក់ងារផ្តល់សេវាសម្រាប់ជនពិការ ដើម្បីឱ្យពួកគេអាចធ្វើការរួមគ្នាក្នុងការផ្តល់ជាជំនួយដ៏ល្អបំផុតដែលអាចធ្វើបានសម្រាប់ជនពិការ។

## តើមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិផ្តល់សេវាអ្វីខ្លះ?

មន្ត្រីសម្របសម្រួលសម្រាប់ជនពិការថ្នាក់ជាតិប្រចាំមូលដ្ឋានរបស់អ្នកនឹង:

- ផ្តល់ព័ត៌មានដល់ជនពិការគ្រប់រូប

- ផ្សារភ្ជាប់ជនពិការម្នាក់ៗនិងអង្គការនានាទៅនឹងសេវាទ្រទ្រង់តាមមូលដ្ឋាន។
- ជួយដល់គ្រឹះស្ថានអប់រំ និងនិយោជកតាម មូលដ្ឋានដើម្បីផ្តល់សេវាដល់ជនពិការឱ្យបាន កាន់តែប្រសើរ។
- លើកកំពស់ការយល់ដឹងក្នុងចំណោមគ្រឹះស្ថានអប់រំ និយោជក និងសាធារណៈជន ទូទៅអំពីបញ្ហាដែលជនពិការប្រឈមមុខ។

## តើនរណាខ្លះដែលនឹងទទួលបានផលប្រយោជន៍?

ជនពិការគ្រប់រូប គ្រួសាររបស់ពួកគេ បណ្តាញទ្រទ្រង់ និងគ្រឹះស្ថានអប់រំក្រោយសាលាចំណេះទូទៅនឹងទទួលបានផលប្រយោជន៍ពីការសម្របសម្រួលដែលបានកែលម្អ និងផ្តល់សេវាទ្រទ្រង់អន្តរកាល។

## តើខ្ញុំរកមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិដោយរបៀបណា?

ដើម្បីរកមន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិ សូមចូលទស្សនា៖

www.deewr.gov.au/ndco

ផលិតដោយ មន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិភូមិភាគ 12 (2011)

RMIT UNIVERSITY

មូលនិធិរបស់មន្ត្រីសម្របសម្រួលជនពិការថ្នាក់ជាតិត្រូវបានឧបត្ថម្ភដោយនាយកដ្ឋានអប់រំ ការងារ និងទំនាក់ទំនងកន្លែងធ្វើការនៃរដ្ឋាភិបាលអូស្ត្រាលី។

Australian Government
Department of Education, Employment and Workplace Relations

NDCO
National Disability Coordination Officer Program